អនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន អោយបានល្អប្រសើរចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រីទី២**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

**សេចក្តីសំរេច**

**លេខ ១៤ សសរ**

**ស្តីពី**

**ការបង្កើត គណៈកម្មការអន្តរក្រសួង បង្ក្រាបការធ្វើ**

**អាជីវកម្មបញ្ចាំង និងលក់កាសែតវីដេអូអាសអាភាស**

**ក្នុងរាជធានីភ្នំពេញ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ និងចាត់វិធានការ បង្ក្រាបរោង បញ្ចាំង វីដេអូអាសអាភាស និងការលក់កាសែ្សត អាសអាភាសទាំងឡាយក្នុងរាជធានី ភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឬតំណាង ជាប្រធាន
២–តំណាងក្រសួងមហាផ្ទៃ ជាអនុប្រធាន
៣–តំណាងក្រសួងការពារជាតិ ជាសមាជិក
៤–តំណាងក្រសួងពត៌មាន ជាសមាជិក
៥–តំណាងសាលាក្រុងភ្នំពេញ ជាសមាជិក
៦–តំណាងតុលាការរាជធានីភ្នំពេញ ជាសមាជិក
៧–តំណាងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ជាសមាជិក
៨–តំណាងលេខាធិការដ្ឋាន កិច្ចការនារី ជាសមាជិក
៩–តំណាងនាយកដ្ឋានភាពយន្ត និងវីដេអូ លេខាធិការ

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច ÷

–តាមដានត្រួតពិនិត្យការអនុវត្តអនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការគ្រប់គ្រងត្រួតពិនិត្យភាពយន្តនិងវីដេអូ ។
–ចូលត្រួតពិនិត្យគ្រប់រោងអាជីវកម្ម បញ្ចាំងភាពយន្ត វីដេអូ ។
–ត្រួតពិនិត្យគ្រប់កន្លែងធ្វើអាជីវកម្ម ជួលលក់កាសែ្សតវីដេអូ ។
–ធ្វើកំណត់ហេតុ រៀបចំសំណុំរឿង លិខិតបទល្មើសពាក់ព័ន្ធ និងរបាយការណ៍ ជូនទីស្តីការ គណៈរដ្ឋមន្ត្រី ។

**ប្រការ ៣** : សមាជិក គណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង ពត៌មាន សាលាក្រុង ភ្នំពេញ តុលាការរាជធានីភ្នំពេញ លេខាធិការដ្ឋានកិច្ចការនារី មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីភ្នំពេញ នាយកដ្ឋានភាពយន្ត-វីដេអូ ដូចមាន

ចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * *

# III - ការងារបណ្ដាក្រសួង

## ១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ប្រកាសលេខ ៣៣០ ឧក.ប្រក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦**

**ប្រការ ១** : អនុញ្ញាតអោយលោក **ង៉ោ គីមហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ២៦៦០៩២ ភព.ចុះថ្ងៃទី ២៣_៣_៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣២ អឺ១ហ្សិត ផ្លូវ លេខ១៦៦ ក្រុមទី ៨៤ សង្កាត់ អូរឬស្សីទី ១ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបើកដំណើរការ ឧស្សាហកម្មតូច ស្លូ និងកិនដែក «ខេមស្ទីល-CAMSTEEL» នៅក្នុងទីតាំង ភូមិជើងឯក សង្កាត់ ជើងឯក ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២** : លោក **ង៉ោ គីមហេង** ត្រូវរៀបចំឧស្សាហកម្មតូច ស្លូនិងកិនដែករបស់ខ្លួន អោយស្រេចជាស្ថាពរក្នុងរយៈពេល ៦ ខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។